Khmer Story Lovers

# បញ្ញាមរណៈ

— ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៤៨ ជីឡូត៍លេខ ២៥៤ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ស៊ុំផាននឹករឭកអាស៊ីវ ស្រមៃឃើញទឹកមុខនាងស្រស់ស្រគាត់នៅពេលបែកគ្នា, ស្រមៃឃើញនាងក្តាប់ដៃខាយផ្តាំថា នាងនឹងចាំមួយខែដូចលោកយាយថែរ... នាយចង់ពាក់ស្លាបហោះទៅជួបអាស៊ីវវិញភ្លាម, ប៉ាយជីតាយ កំពុងជក់អារម្មណ៍ នឹងយុទ្ធសិល្បៈលើជញ្ជាំងហើយ មិនអាចទាញគាត់ទៅតាមឡើយ ។

មាណពមិនហ៊ានរំខានលោកតា ក៏ដើរបន្ទួសទៅ. បន្ទប់ទី៣ ។ បន្ទប់នេះមានស្រមឹកខ្យល់ខ្លាំងក្លា គឺតាចាស់បីរូបកំពុងសំដែងគុនសម្រាលខ្លួនតែប្រណាំងគ្នាពេញបន្ទប់បណ្ដើរ ដដែកគ្នាឲ្យឮបណ្ដើរ ។ ប៉ុន្តែគួរចំឡែកត្រង់គាត់ដកដង្ហើមដូចធម្មតា ហាក់គ្មានហត់ហត់បន្តិចណាសោះ សឲ្យយល់ថាតាទាំងបីរូបមានកម្លាំងកាយស្ទុះស្ទួមដូចគ្នា ។

ស៊ុំផានទៅដល់ភ្លាម តាចាស់ម្នាក់ពោល:

-កំណាព្យបុរាណនេះជាស្នាដៃកវីនិពន្ធនាម លីថៃប៉ាយ ជាអ្នកអក្សរសាស្ត្រសោះ, ម៉េចតែងកំណាព្យទាំងប៉ុន្មានវគ្គមានន័យជ្រៅជ្រះខាងយុទ្ធសិល្បៈទៅវិញ ?

តាចាស់ម្នាក់ទៀតឆ្លើយ :

-អាហ្នឹងហើយដែលត្រូវសរសើរ ! គេចេះតែងកំណាព្យបញ្ឆិតបញ្ឆៀង ឬបង្កប់ស្នៀតគួរឲ្យពិបាកយល់បែបហ្នឹង តើរូប

អ្នកប្រែសម្រួល អ.គីមសាន

តម្លៃ ៣០៛

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

«មាតុភូមិ»

ភ្នំពេញ

លេខ ៤៦

គេផ្តល់មានយុទ្ធសិល្បៈ ប៉ុណ្ណា ?

តាចាស់ទីបីងក់ក្បាលយល់ស្រប៖

– លោកបងមានប្រសាសន៍ត្រូវហើយ, តែពាក្យ «សេះសកែបប្រាក់» មានន័យថាម្តេចទៅ ?

តាចាស់ទីមួយមានគំនិតដូចគ្នាពោលថា :

– មែន ! បើតាមខ្ញុំយល់ពាក្យនេះត្រូវតាក់តែងនឹងឃ្លាមួយខាងបន្ទប់ទីបួនដែលថា « វាយោធោកផ្កាយរះ» ទៀតផងណា ! ពេលនេះយើងស្រាវជ្រាវវិជ្ជាគុនមិនត្រូវរែកញែកអក្សរសាស្ត្រទេ, សុំកុំប្រកាន់ពាក្យមួយម៉ាត់ៗ យកត្រូវរៀនខ្លួន ។

ស៊ីផានចូលណាស់នឹកថា: តាចាស់ទាំងបីរូបនេះដណ្តើមគ្នាពីរឿងសៀវគុន ម៉េចមិនអង្គុយឲ្យស្រួលបួលបែរជាវក់ប្រដេញគ្នាវិលវល់ក្នុងបន្ទប់ដូចកន្ទុះឡោះទៅវិញ ។

ភ្លាមនោះតាចាស់មួយរូបបន្លឺថា៖

– លោកបងប្អូនកាន់ជាយល់ពាក្យពីរឃ្លានេះច្រើនជាងខ្ញុំ ហេតុអ្វីពេលនេះបងដេញខ្ញុំមិនទាន់សោះ ? មាណពឮវាចានេះទើបយល់រឿង ។ តាចាស់ទីមួយសើច៖

– ចុះលោកបងតាមខ្ញុំទាន់ដែរ?

តាចាស់ទាំងបីគ្រៀកគ្រឡឹងជុំវិញបន្ទប់ដេញខ្យល់ព្រឹបៗដោយអាការប៉ុងរំភើយៗ តែដូចដេញគ្នាទាន់សោះ សឲ្យមាណពយល់ថា លោកតាមួយណាក៏ដេញពួកម៉ាកគាត់ឥតទាន់ដែរ ព្រោះកំរិតគុនសម្រាលខ្លួនគាត់ប្រហាក់ប្រហែលគ្នាពេក ។

ស៊ីផានងើយមើលគំនូរលើជញ្ជាំងឃើញរូបសេះមួយ ងើបក្បាលផាយយ៉ាងសង្ហាលើផ្ទៃពពកខ្ពស់ ខ្ញាញ់ទំនងជាសេះបេះហោះហើរលើអាកាស ។ មាណពបង្ខឹងក៏ធ្វើត្រាប់តាមកាយវិកាសេះមុន, ស្រាប់តែធាតុក្តៅក្នុងខ្លួននាយស្ទុះទៅមួយកន្លែងគួរឲ្យបារម្ភ ។ នាយនឹកម៉ាក់ងឹងថា របៀបហាត់រៀនតាមគំនូរនេះខុសពីគំនូទីមួយនិងទីពីរ ។

នាយពិនិត្យជុំពពកក្រោមជើងសេះម្តងឃើញដូចជាគ្រស៊ុះគ្រសាយវិស័យដូចពពកមែនទែន, មានខ្វះហាក់ចង់ផុសចេញអណ្តែតផុតពីជញ្ជាំងចុះផង ។ សម្ងំមើលយូរទៅកម្លាំងធាតុទាំងប៉ុន្មានក្នុងខ្លួននាយជ្រួលច្របល់យ៉ាងខ្លាំងឈរមិនសុខសោះ ទាល់តែរត់និងគេដែរ ។ មាណពរត់មួយជុំក្រឡេកមើលជុំពពកម្តងហើយរត់មួយជុំទៀត ។ រត់ចុះឡើងដំណើរនាយក្រេកក្រោតដូចមនុស្សស្រវឹងស្រា ។

តាចាស់បីនាក់តែមួយសន្ទុះទៀតទើបឈប់បកមើលស៊ីផានរត់ម្តង, គាត់ហាក់ឃើញមាណពរត់យឺតណាស់, ប្រហែលប្រាំពីរប្រាំបីជុំទើបស្មើពួកគាត់មួយជុំ ។ តាចាស់អត់មិនបាននាំគ្នាពោលចំអក :

– យុវជនក្មេងវ័យសនេះមកពីណា ហ៊ានហាត់រត់ប្រណាំងជួបយើងដែរ, មិនខ្មាសមទេ, មិត្តកួច ! ហាសៗ !

– គួរសម្រាលខ្លួនកំពស់ហ្នឹងកុំត្រដរហាត់រៀនតាមគំនូរលើផ្ទាំងថ្មគឺ, នៅខ្វះច្រើនណាស់ !

– ទោះបីយុទ្ធសិល្បៈស្រវឹងស្រាក៏ត្រូវមានសភាពល្អស្រស់ដំណើរឃ្លានជាងនេះដែរ, ឯដំណើរក្មេងនេះដូចក្អកល្ហុងអ៊ីចឹងហ្ន៎ ! ហាសៗ..

ស៊ីផានមុខក្រហមឆាំងរលៃតែរត់ច្រើនជុំផុតស្តាប់តាចាស់ទាំងបីទៀយ ។ អារម្មណ៍នាយនៅមូលផ្តុំលើរូបសេះ, ភ្នែកនាយក្រឡេកមើលតែជុំពពក ។ កាលណារត់ដល់គំនូរ នាយរកឈប់មិនបានសោះ. ទេះតែបង្វិលរត់តាមគំនូរពពក, ម្ល៉េះហើយនាយរត់ច្រើនជុំ, រត់មើលទាល់តែចាំស្ទាត់ ទើបព្រមឈប់ ។ តាចាស់ទាំងបីទៅឯណា បាត់ឃើញឯបុរសប្អូនរូបកាន់ដាវចូលមកធ្វើក្បាច់តាមរូបសេះលើផ្ទាំងទៅវិញ ។

បុរសទាំងប្អូនប្រឡូកគ្នាបណ្ដើរកានអក្សរក្បួរគំនូរបណ្ដើរ ។ ពេលនេះ ស៊ីផានឮជនម្នាក់សូត្រខ្លាំងៗ :

–ពន្លឺប្រាក់ភ្លឺថ្លា... កែបសេះភ្លឺលោងលើខ្នង...

ម្នាក់ទៀតអាន :

–ពន្លឺចាំងខាងលើ... ខាងក្រោមដារជ្រោះខ្មៅក្រប !

ស៊ីផានគិតថា :

– ពាក្យអស់នេះមិនដឹងមានន័យយ៉ាងម៉េចទេ យើងឥតយល់ទាល់តែសោះ " ។ រីបុរសទាំងប្អូនពិតជាមកមើលគំនូរមុនយើង, បើមិនសាបសិបឆ្នាំក៏ម្ភៃប្ដូរដប់ឆ្នាំមុនដែរ ។ គេមកមុនមិនយល់ទៅហើយយើងចំស្តាប់ធ្វើអី ? គ្រាន់តែដើរមើលលេងត្រួស ៗ រង់ចាំបបួលលោកតាទៅផ្ទះវិញបានហើយ ។

មាណពដើរទៅបន្ទប់ទីប្អូនដែលមានកំណាព្យមួយឃ្លាថា « រាយោរបាកផ្កាយ រះ „ ក្បែរគំនូរ

Khmer Story Lovers



ដូចបន្ទប់ឯទៀត ។ មាណពហាត់រៀនតាមការយល់រៀងខ្លួនពីបន្ទប់មួយទៅបន្ទប់មួយ ។ ក្បួនកំណាព្យបុរាណនោះមានម្ភៃបួនឃ្លា ទើបគេចែកបន្ទប់ជាម្ភៃបួនសម្រាប់ដាក់កំណាព្យ មួយឃ្លាក្នុងបន្ទប់មួយ ។

ស៊ុំផានមិនចេះអានអក្សរទេ នាយហាត់ហ្វឹកហ្វឺនតាមគំនូសនៃគំនូរលើជញ្ជាំងដោយឥតរវល់អក្សរផងទេ ។ ក្នុងកំណាព្យបុរាណនេះមានឃ្លាខ្លះបង្ហាត់បង្រៀនពីស្នៀតគុនដាវ, ស្នៀតវាយប្រយុទ្ធ,វិធីសម្រាលខ្លួន, វិធីចំរើនកម្លាំង ។ល។ ក្នុងចំណោមគំនូរទាំងម្ភៃបួនមាណពមើលបានយល់ខ្លះ ក្រយល់ខ្លះ ។ ជួនកាលនាយហាត់តាមបានពីរបីបន្ទប់, ជួនកាលប្រាំពីរប្រាំបីថ្ងៃមិនទាន់ត្រូវគ្រប់តាមគំនូរមួយផង ។ នាយហាត់រហូតដល់បន្ទប់ទីម្ភៃឥតដឹងពេលវេលាកន្លងដល់ណាឡើយ ។

នាយបានគឿនប៉ាយជីតាយបបួលទៅផ្ទះម្ដងៗដែរ, តែប៉ាយជីតាយមើលគំនូរយូរៗកែតែជក់ចិត្តខ្លាំងឡើងភ្លេចយាយស៊ុំអស់រលីង ។ គ្រាន់តែឃើញមាណពដើរទៅជិត គាត់ស្រែកជេរសព្វគ្រប់ថា នាយរំខានចិត្តនិងធានៅមិនឲ្យគាត់ស្រាវជ្រាវយុទ្ធសិល្បៈដ៏ចំណាន មានពេលខ្លះគាត់លើកដៃគ្រវីប្រុះ ឲ្យទំនិយាយរកគាត់ផង ។

ស៊ុំផានមិនដឹងគិតយ៉ាងណា ក៏ដើររកហ្វានយីហ្វៃនិងលោកស្រីកាវសានលានជី សួរយោបល់ៗ ប៉ុន្តែអ្នកតាហានខានលាវគុនទាំងអស់ ក៏ល្ងក់វង្វេងនឹងក្បួនយុទ្ធសិល្បៈលើជញ្ជាំងដូចតាប៉ាយដែរ ។ មានម្ដងនោះព្លេកហ្វានយីហ្វៃហៅនាយទៅស្ដាប់ពាក្យពន្យល់ពែក នាំសេចក្ដីមួយឃ្លា នៃកំណាព្យបុរាណផង ។ ប៉ុន្តែមាណពមានការប្រុងប្រយ័ត្នជាពិសេសនឹកថា :

-ម្ចាស់កោះវៃផ្ដាំពួកយើងថាអាចចាកចេញពីកោះពេលណាថ្ងៃណាក៏បាន, តែយើងមើលភ្ញៀវទាំងអស់ឃើញជក់ចិត្តភ្លេចផ្ទះសំបែង ដោយសារការស្រាវជ្រាវក្នុងបន្ទប់ថ្មអស់នេះតែម្ដង ។ សាមសិបឆ្នាំគ្មានឃើញលោកណាដាច់ចិត្តដើរចេញពីបន្ទប់អស់នេះសោះ អាចបញ្ជាក់ឲ្យដឹងថា អក្សរនិងគំនូរលើជញ្ជាំងមានឥទ្ធិពលបំផុតទាក់ទាញចិត្តអ្នកគុននិយមឲ្យក្រាញនៅទីនេះស្រាវជ្រាវតទៅទៀត, រូបយើងសំណាងល្អខុសគេ មកពីយើងនៅក្មេងចេះតិចតួចហើយមិនចេះអានអក្សរទើបមិនជាប់ជំពាក់ចិត្តដូចគេ ។

មាណពយល់ឃើញបែបនេះបានជាមិនយកចិត្តទុកដាក់ស្ដាប់ហ្វានយីហ្វៃពន្យល់កំណាព្យទេ, នាយរកលេសផ្សេងៗដើរចេញពីមុខពីមាត់គេហើយបំភ្លេចសេចក្ដីពន្យល់អស់រលីងទៅ ។ នាយកប់បុះ

ឡើងឃើញថាមកដល់កោះឡុងមុខបានចំនួនជាង៥ថ្ងៃ, ហើយសល់មិនដល់ដប់ថ្ងៃទៀតនាយត្រូវត្រឡប់ទៅវិញជាដាច់ខាត ។

នាយនឹកឃើញម្យ៉ាងទៀតថា បានចូលគ្រប់ផ្ទៃបីបន្ទប់ ហើយនៅសល់បន្ទប់មួយគត់ដែលត្រូវចូលទៅមើលតាមបុប្ផាថ្ងៃជាកិច្ចបង្ហើយ ។ បើម៉ាយជីតាយមិនព្រមត្រឡប់ទៅវិញ, នាយត្រូវទៅម្នាក់ឯងយករឿងចម្លែកនៅទីនេះទៅរ៉ាយរ៉ាប់ប្រាប់យាយស៊ីនិភកាស៊ីវឲ្យដឹងសេចក្តី ។

មាណពដើរចូលបន្ទប់ទី៤ថ្ងៃបួនស្រាប់តែឃើញម្ចាស់កោះត្រកូលឡុងនិងមុ អង្គុយពែនភ្នែនលើខ្នើយ បែរមុខទៅរកជញ្ជាំងថ្មសញ្ចប់សញ្ចឹង យ៉ាងស្ងៀមស្ងាត់ ។ ស៊ុមផានគោរពកោតខ្លាចម្ចាស់កោះទាំងពីររូបណាស់មិនហ៊ានចូលទៅទៀតឡើយ ។ លុះក្រឡេកមើលជញ្ជាំង នាយភ្ញាក់ខ្លួនព្រឺតក្បាលម្តងព្រោះបន្ទប់ទីបួនឥតមានគំនូររូបមួយសោះ , លើជញ្ជាំងសុទ្ធតែអក្សរគួរសម្រេចចិត្តថា:

— ក្នុងបន្ទប់នេះគ្មានស្អីមើលទេ, យើងត្រូវត្រឡប់ទៅរកលោកតាជំរាបលោកឲ្យចេញពីកោះនេះតែម្តង ។

ស៊ុមផានស្រវៃដល់ពេលជួបអាស៊ីវធាប់ៗ ជួបយាយស៊ីព្រមទាំងប្តីប្រពន្ធស៊ីឈីង....

នាយបន្ទន់កាយសំពះម្ចាស់កោះបីដងព្រមទាំងបន្លឺវាចា :

— ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះលោកម្ចាស់ទាំងពីរ ដែលបានអនុញ្ញាតឲ្យខ្ញុំមើលស្នៀតគុនលើជញ្ជាំងថ្ម ។ ថ្ងៃនេះខ្ញុំបាទសុំលាលោកម្ចាស់ត្រឡប់ទៅវិញហើយ ។

តាចាស់ទាំងពីរនាក់សម្ងំសម្ងក់ជញ្ជាំងនៅស្ងៀមឈឹងឥតព្រាប់ពាក្យកម្ដោះទេ ។ មាណពពេលភ្នែកតាមលោកតាទាំងពីរឃើញអក្សរលើជញ្ជាំងពត់ពេនរវាំងជួបស្រើរបាំ បណ្ដាលឲ្យព្រិលភ្នែកមួយរំពេច ។ នាយច្រូចភ្នែកសម្លំបន្តិច ទើបបើកមើលអក្សរទាំងនោះម្តងទៀត , នាយស្រវាំងភ្នែកដដែល ពាល់តែងាកមុខចេញពិការណាថា:

— អក្សរគឺចង្រៃក្រម៉ះ ? គ្រាន់តែមើលក៏ស្រវាំងភ្នែក ?

មាណពមិនអស់ចិត្តសោះឈាននៅមុខថែមហើយខំសម្លឹងអក្សរម្តងទៀត ។ ពេលនោះអក្សរនីមួយៗហាក់ក្លាយជាសត្វដង្កូវនាងរតើមលើជញ្ជាំងថ្ម, តែបើខំពិនិត្យមើលទៅវាដង្កូវប្រែក្លាយជាអក្សរដេកស្ងៀមវិញ ។

មាណពនឹកដល់ពេលនាយនៅតូច ចាប់សត្វដង្កូវធ្វើនុយស្ទូចត្រីក្នុងស្រះកែអង្វុក, នាយ

Khmer Story Lovers

ចាប់អារម្មណ៍ដូចបានជួបកូនស្នេហ៍ដ៏ច្រើនគួរសប្បាយ ទើបបណ្ដោតខ្សែបក្ខុមើលតួអក្សរ ម្ដងខ្លួន ម្ដងមួយៗ ។ លុះមើលយូរ ៗ ទៅស្រាប់តែជីពចរលើខ្នងញាក់ញើក ៗ ដូចកាលនាយមើល រូបគំនូរក្នុងបន្ទប់ឯទៀតដែរ ។ នាយនឹកថា :

–យីអើ ! អក្សរដូចផ្កាភ្លើងនេះមានទាក់ទងដល់ជីពចរ និងកម្លាំងធាតុក្នុងខ្លួនយើងទៀតហើយតើ !

នាយសម្លឹងអក្សរមួយតួទៀត, ជីពចរត្រង់បង្កើះញាក់ញើក, មើលដល់តួអក្សរទីបីឥតមាន ប្រតិកម្មអ្វីសោះ ។ នាយប្រុងមើលតទៅទៀត ស្រាប់តែឮសម្លេងមួយដ៏សោះកក្រោះបន្ទីក្បែរ ត្រចៀកថា :

– លោកនាយក្រុមស៊ីពិនិត្យអក្សរយ៉ាងយកចិត្តទុកដាក់បែបនេះប្រហែលស្គាល់ជំនាញខាងបាលី ច្រើនហើយមើល៍ទៅ !

មាណពងាកមកឃើញម្ចាស់កោះត្រកូលមុឈរបើកភ្នែកមូលក្លំសម្លឹងមុខនាយដោយពន្លឺមុត ។

នាយសម្រួលទឹកមុខភ្លាមឆ្លើយថា :

– ខ្ញុំបាទមិនចេះអក្សរមួយតួទេ, គ្រាន់តែឃើញក្រវេមក្រវាមមើលលេងទៅ ។

ម្ចាស់កោះងក់ក្បាល:

– អឺចឹងទេ ! នេះជាបាលីជំនាន់ដើមសុទ្ធសាធណា៎ ខ្ញុំកំពុងតែត្រិះរិះមើលមិនយល់សោះ ។ លោកនាយក្រុមស៊ីនៅក្មេងចេះអក្សរបម្លែកដែរហ្ន៎ !

ស៊ីផានប្រេះប្រៀនឆ្លើយទាំងអៀនខ្មាស់:

– ខ្ញុំបាទលែងហ៊ានរំខានលោកម្ចាស់ទៀតហើយ ។

នាយងាកក្រោយប្រុងដើរចេញ តែតាត្រកូលមុឃាត់ :

– មិនអីទេ, សូមលោកនាយក្រុមនៅមើលលេងទៀតចុះ , គ្មានអ្វីគួររំខានដល់យើងខ្ញុំទេ ។

ពោលចប់តាចាស់ផ្ទេចភ្នែកស្ងឹងស្ងាធដូចដើម ។ ស៊ីផានគិតថា បើចេញទៅភ្លាមក្រែង ម្ចាស់កោះអន់ចិត្ត ម្ល៉ោះហើយនាយឈរមើលបន្តិចទៀត ។ គ្រាន់តែងើយមើលអក្សរមួយតួ ភ្លាម ជីពចរត្រង់ពោះលោតញើកៗញ័រញាក់ដល់សរសៃសរសួងដូចគេគក់ប្រដាប់ចាប់សរសៃធ្វើឲ្យស្រួល ខ្លួនអឺចឹង ។

មាណពផណ្ដឹងសួរ :

PERCEVO

- ហេតុអ្វីក៏មានអក្សរបម្លែកបែបហ្នឹង ?

ពេលនេះនាយចាប់ចិត្តលើអក្សរក្រវេចក្រវមបន្តិចហើយ, កាលណាមើលច្បាស់មែនទែនអក្សរបែងតំរើកភ្លុកលែងព្រិលជីពចរនាយតែងលោតញ្ញើក ។ ស្រាលខ្លួនគួរកេកយណាស់ ។ អក្សរលើជញ្ជាំងមានចំនួនរាប់ពាន់ ហើយក្នុងអក្សរមួយៗ មានគំនូសបួនជប់ទៀតធ្វើឲ្យសរសៃជីពចរនាយធ្វើចលនាប្រតាក់ប្រតាញគ្នាស្រួលខ្លួនឡើងទៀង ។

ស៊ីផានពិនិត្យអក្សរភ្លេចភ្លាំងស្មារតី, ភ្លេចសំដីម្ចាស់គោរព្រកួលមុតតែសង្កេតអក្សរយូរហើយ ដើម្បីឲ្យសរសៃជីពចរលោតជាប់ៗគ្នាដើកស្រួលខ្លួនឡើងទៀង ។. ប៉ុន្តែដោយហេតុអក្សរមានចំនួនច្រើនពេក នាយមិនអាចខំបំពេញបំណងបានក៏ឈប់មួងៗរកជង្ហើម ។ មាណពព្យាយាមមើលអក្សរតាំងយប់តាំងថ្ងៃលែងស្គាល់ពេលវេលា, កាលណាឃ្លាននាយរកចំណីអាហារផ្លែឈើស៊ីក្បែរនោះទទួលទាន ។ មិនដឹងជាអស់ពេលប៉ុន្មានថ្ងៃ, ស៊ីផានរាប់ឃើញថា នាយបានបរិភោគចំណីអាហារជប់ប្រាំបីដងឯជីពចរក្នុងខ្លួនក៏លោតជាប់គ្នាដើកបានយូរជាងមុនដែរ ។

នាយមានអារម្មណ៍ថ្លែកដូចសត្វជន្លេនរាប់ពាន់កំពុងវារគតេមសព្វប្រាណនាយ តាមជីពចរនីមួយៗ ។ នាយអរចង់ក្អួយជងដោយដឹងខ្លួនថាបានល្អក់ចិត្តនឹងអក្សរលើជញ្ជាំងដូចក្មេងឯទៀតដែរ ។

មាណពសម្លឹងជញ្ជាំងមិនដាក់ភ្នែក, កាលណាអស់កម្លាំងទើបផ្អែកខ្លួននឹងជញ្ជាំង, ដឹងខ្លួនកាលណាបើកភ្នែកមើលទៀតឃើញអក្សរដដែលៗ ។

ពេលវេលាចេះតែកន្លងទៅសន្សឹមៗ.. យប់ហើយថ្ងៃៗហើយយប់ទៀត ។

ថ្ងៃមួយស្រាប់តែកម្លាំងធាតុក្នុងខ្លួននាយកើនឡើងដូចជាពុះកញ្ជ្រោលជណ្តើមគ្នាចេញ តាមសរសៃជីពចរមកខាងក្រៅ ។ កម្លាំងធាតុនោះក្តៅខ្លាំង ។ ធ្វើចលនារហ័សក្រៃលែងប្រៀបដូចទឹកហូរពីដៃទន្លេចាក់ក្នុងសមុទ្រ ។ មាណពបុកពោះភឺបៗ មិនដឹងកើតការប្រែប្រួលក្នុងខ្លួនម្តងនេះមានប្រយោជន៍ល្អឬផ្តល់គ្រោះថ្នាក់ឲ្យនាយដូចលើកមុន តែទោះបីយ៉ាងណាកម្លាំងធាតុក្តៅខ្លាំងៗនេះមិនចេញមកក្រៅសោះ ។ ស៊ីផានគប់ប្រមល់ក្នុងទ្រូងពេកក៏គ្រវាសដៃចាប់សំដែងស្នៀតគុនតាមរូបគំនូរក្នុងបន្ទប់ទីដប់ពីរ ដែលមានកំណាព្យមួយឃ្លាថា «រួចកិច្ចត្រូវលាសំដៃ» ។

កាលបើបានបញ្ចេញស្នៀតនេះមក, កម្លាំងធាតុកើនឡើងមួយកម្រិត, នាយហោះដៃសំដែងស្នៀតគុនជាវតាមគំនូរទីប្រាំដែលមានឃ្លាកំណាព្យថា «ដប់ជំហានសម្លាប់មនុស្សម្នាក់» នាយគ្មាន

កាន់តាវុធក្នុងដៃមែន, តែខ្យល់ដែលចេញពីកាយវិការបញ្ចេញស្នៀតនោះ មានឥទ្ធិពលខ្លាំងក្លាណាស់ ខ្ទរពេញបន្ទប់ថ្ម ។

## ខគ្គទី ៤២

## ស៊ីផឆានជាកូនអ្នកណា?

ក្នុងពេលសំដែងស្នៀតដាវ ដប់ដំហានសម្លាប់មនុស្សម្នាក់នោះ សាច់ដុំនាយឡើងប៉ោងចន់ប្រេះក្លាយដោយហេតុកម្លាំងធាតុពុះកញ្ជ្រោលពេញបន្ទុក ។ មាណពរឹតតែសប្បាយក្អេងក្អាងទាំងអស់ ជុំវិញខ្លួនក៏ហាត់តាមគំនូរទីមួយឈ្មោះថា «កៀវពាក់កន្ទិបខៀវ» ដោយលើកដៃគ្រវីគ្រវាត់ដូចជាសប្បាយរីករាយផង, តប់ប្រមល់ក្នុងចិត្តផង ។ បន្ទាប់ពីធ្វើគ្រាប់តាមកៀវពាក់កន្ទិបខៀវ, នាយសំដែងស្នៀតកណ្ដៀវសស្វាចទៀត ។

ពេលនេះគំនូរទាំងអម្បាលម៉ាននៅលើជញ្ជាំងថ្ម បានប្រជ្រៀតគ្នាលេចក្នុងអារម្មណ៍នាយ ។ អស់ពី « សេះសកែបប្រាក់ » ក្នុងបន្ទប់ទីបីដល់ « អ្នកណាកេបប្រាប់បាន » ក្នុងបន្ទប់ទីម្ភៃបី ស្នៀតគុនដាវ គុនកាំបិត, យុទ្ធសិល្ប៍ : ចំរើនកម្លាំងកាយ,សម្រាលខ្លួននិងទ្រឹស្ដីផ្សេងៗ បញ្ចេញរូបរាងជាមួយគ្នាក្នុងពេលតែមួយ ។ ស៊ីផឆានបានសំដែងយុទ្ធសិល្បៈ តាមគំនូរតាំងពីក្បួនទីមួយដល់ក្បួនទីម្ភៃបីទាំងមិនដឹងខ្លួនថែមទាំងឥតបែងចែកជាវគ្គជាប្រភេទផង ។

លុះហាត់ដល់គំនូរទីម្ភៃបី កម្លាំងធាតុនាយរត់បញ្ច្រាសមកវិញ, មាណពត្រូវហាត់សាពីក្រោយមកមុខម្ដងទៀតជាចាំបាច់ ដោយធ្វើគ្រាប់តាមគំនូរទីម្ភៃពីរមានឃ្លាកំណាព្យថា « ខ្មាសអៀនក្នុងលោកនេះ » ដល់ឃ្លាទីមួយមានរូបកៀវពាក់កន្ទិប ។ ពេលនោះនាយស្រែកហ៊ូចភ្លេចសំដែងសេចក្ដីរីករាយសប្បាយឥតប្រៀបបាន ។

ក្នុងពេលជាមួយគ្នានាយនឹកឃើញចំណេះទាំងអស់ដែលបានរៀនពីតូច មានវិជ្ជាធាតុព្រះជាក់ ទេះពីម្ដាយ វិជ្ជាក្ដៅឧណ្ហៗទេះពីស៊ីយានទី យុទ្ធសិល្បៈនៃកូនឥក្កតា, ស្នៀតចាប់ខ្នាំរបស់ទីងកង, គុនដាវក្ដីគកក ស្នៀតគុនខាងអាស្រមសាំងលីនរចេះពីប្ដីប្រពន្ធស៊ីឈីង គុនប្រដាល់ទះតប់របស់ទីងមិនហួសបួន គុនកាំបិតគ្រុមព្រះអាចារ្យរបស់យាយស៊ី ព្រមទាំងស្នៀតប្លែកៗដែលនាយបានរៀនខ្លួនឯង លើកោះផ្សែងខ្មៅ...

មាណពបញ្ចេញកាយវិការពាបតែទឹកឃើញឥតមានសណ្ដាប់ធ្នាប់បែន,  តែហាក់ដូរដៃដូរជើងដូចបេះដូងនិងស្មារតីធ្លាក់មកអីចឹង ។ ចង់បញ្ចេញស្នៀតមួយណា, នាយមិនបាច់គិតមុនឬប្រមូលកម្លាំងឲ្យមូលផ្ដុំឡើយ ។ ស៊ីផានត្រេកអរពេកស្រែកហៅម្ចាស់ឯងផ្ទុះសំណើចក្អាកក្អាយ :

– ហាស ។ ... អស្ចារ្យណាស់ !

ស្រាប់តែមានសម្រែកមនុស្សពីរនាក់ហៅចន្ទ័រវែរថា : ពិតជាអស្ចារ្យមែន !

មាណពភ្ញាក់ព្រើតទប់ខ្លួនឈរស្ងៀមភ្លាម ។ ម្ចាស់កោះឡុងមុយកៀនជញ្ជាំងម្នាងម្នាក់ចៅលក្ខ័កសម្ដីមកយ៉ាងចំឡែក ។

មាណពលំអោនកាយគោរព :

– សូមអស់លោកទាំងពីរមេត្តាអភ័យទោសឲ្យខាងផង ។

ដល់ពេលនេះ នាយមើលច្បាស់ឃើញម្ចាស់កោះបែកញើសប៉ុនៗគ្រាប់ពោតដូចគ្នា, ខោអាវសោតក៏ទទឹកជោក, ឯជញ្ជាំងនិងក្រោមក្រោមជើងគាត់ ក៏មានដក់ញើសដែរ ។

ម្ចាស់កោះត្រកូលឡុងលើកដៃជូតថ្ងាសហើយតប:

– លោកនាយក្រុមស៊ីពិតជាអ្នកប្រាជ្ញដ៏ពូកែអស្ចារ្យមែន, ខ្ញុំសុំជូនពរយ៉ាងស្មោះចំពោះជោគជ័យរបស់លោកក្នុងថ្ងៃនេះ ។

ពោលចប់ស្រាប់តែលុតជង្គង់គ្រឹបសំពះនាយផ្ដួម ។, តាចាស់ត្រកូលមុក៏ធ្វើតាមគាត់ដែរ ។

ស៊ីផានភ្ញាក់ក្រញាង ម្ដីម្ពាលុតជង្គង់ក្រាបក្បាលដល់ដីសំពះតបវិញញុឹប ។ :

– អស់លោកធ្វើដូច្នេះស្លាប់.. ស្លាប់ខ្ញុំបាទហើយ ។

តាត្រកូលឡុងតប :

– សូមលោក... លោកនាយក្រុមស៊ីអញ្ជើញក្រោក

ស៊ីផានក្រោកឈរ,ម្ចាស់កោះទាំងពីរក៏ក្រោកឈរដែរ, តែតាឡុងញ័រជង្គង់អុកតួចទៅវិញជាបន្ទាន់ តាចាស់ត្រកូលមុច្រត់ដៃទប់ខ្លួនតែក្រោកមិនរួចទៀត ។ មាណពភ្ញាក់ព្រើតម្ដងទៀតសួរថា

– លោកទាំងពីរកើតអីទៅហើយ ?

ព្រមទាំងស្ទុះទៅជួយគ្រាហ៍ម្ចាស់កោះទាំងពីរឲ្យអង្គុយតែនក្អែនស្រួលបួលផង ។

តាចាស់ត្រកូលឡុងឈ្ងប់ភ្នែក បម្រើនកម្លាំងគ្រវីក្បាលមួយៗញញឹមស្ងួត ។ តាចាស់ត្រកូលមុលើកដៃប្រណម្យសម្ពះស្ងៀមឈឹង ។ ស៊ីផានមិនហ៊ានរំខានគាត់ទេ, នាយរើកទៅឈរម្ខាងទាល់តែតាចាស់ត្រកូលមុងគងផ្ដើមយូរក្រោកឈរកៀកស្រវ៉ុបតាត្រកូលឡុង ទើបនាយភ័យស្ទុះងាកមើលតាឡុងស្រវ៉ុបតាមុវិញ ហើយបបួលគ្នាសើចក្អាកក្អាយបញ្ចេញអាការៈរីករាយ ។ មាក់ពពាតភ័យតែនៅឆ្ងល់មិនដឹងគាត់សប្បាយរឿងអី ។ ទីបំផុតនាយសើចជាមួយគាត់ដែរ...

មួយសន្ទុះធំទើបតាឡុងតោងផ្ញើនថ្ងូរក្រោកឈរសន្សឹមៗព្រមទាំងពោលថា :

- លោកនាយក្រុមអើយ ! ក្ដីនឿនឆ្ងល់ទាំងប៉ុន្មានដែលកប់ក្នុងដួងចិត្តយើងជាយូរមកហើយបានត្រូវលោកនាយក្រុមជួយបកស្រាយក្នុងថ្ងៃនេះអស់ហើយ ។ ខ្ញុំបាទមានចិត្តរីករាយណាស់, សុំថ្លែងអំណរគុណយ៉ាងស្មោះចំពោះប្រាជ្ញាលោកនាយក្រុម ។

ស៊ីផានទៅជាមិនមាំងសួរវិញ:

- ម៉េច...ម៉េចលោកថាខ្ញុំជួយបកស្រាយទៅវិញ ?

តាឡុងសើចញញឹម :

-សូមលោកនាយក្រុមកុំដាក់ខ្លួនពេក ។ លោកបានដោះស្រាយរូបគំនូរនិងកំណាព្យបុរាណតាំងពីដើមដល់ចប់អាចបញ្ជាក់ឲ្យយើងខ្ញុំយល់ច្បាស់ថា លោកជាវីរបុរសក្លាហានទីមួយក្នុងពិភពគុនក្នុងសម័យយើង : ។ ក្រៅពីបុព្វបុរសអ្នកចងក្រងយុទ្ធសិល្ប:ចំណាននេះ, យើងខ្ញុំជឿជាក់ថាឥតមានអ្នកណាប្រៀបផ្ទឹមនឹងលោកនាយក្រុមបានទេ ។

ស៊ីផានភិតភ័យណាស់ប្រកែកភ្លាម :

ខ្ញុំមិនហ៊ានទទួលទេ ! បើលោកតាខ្ញុំឮប្រសាសន៍លោកដូច្នេះគាត់ខឹងប្រទេ្បាតហើយ !

- យ៉ី មកពីហេតុអីដែរបានជាគាត់ខឹង ?

-បាទ, លោកតាខ្ញុំឲ្យគេថាគាត់ជាជើងឯកលើអ្នកគុនឱយមទាំងអស់, តាំងពីគុនដាវ អាវុធសម្ងាត់, កម្លាំងធាតុ រហូតដល់ក្ដៅឈ្មោះស្អី ១ ទៀតទេ ។ ចំណែករូបខ្ញុំមិនចេះអីសោះ, ទៅប្រៀបផ្ទឹមនឹងគាត់ម្ដេចបាន ?

តាចាស់ត្រកូលឡុងសើចហោស ៗ :

- អូ ! វីរបុរសក្លាហានគ្មានពីរក្នុងលោកយើងនេះជាប៉ាយជីហាយនាយក្រុមក្នុងទឹកកកទេតើ !

Khmer Story Lovers



គាត់ងាកញញឹមដាក់ម្ចាស់កោះត្រកួលមុំហើយសួរមាណពទៀត :

– ចុះលោកនាយក្រុមស៊ុមានយោបល់បែបម៉េចដែរ

ស៊ីផានសញ្ជប់សញ្ជឹងមួយសន្ទុះទើបឆ្លើយ :

– លោកតាប៉ាយពិតជាមានគំនេះវិជ្ជាខ្ពង់ខ្ពស់មែន, តែដែលថាគាត់ជាអ្នកក្លាហានលើសមួយនោះប្រហែលជាមិន ... មិនសូវសមទេ ។

ម្ចាស់កោះត្រកួលឡើងងក់ក្បាល :

–មែនហើយ ! បើនិយាយពីស្នៀតគុនជាវិជ្ជាកម្លាំងកាយ, យើងហានអះអាងថាលោកនាយក្រុមស៊ុមានកម្រិតខ្ពស់ជាងលោកតាប៉ាយប្អូនជប់ភាគ ។ ចំណែកកំណាព្យបុរាណនេះ សុទ្ធជាពាក្យបាលី, យើងខ្ញុំពីរនាក់បងប្អូនមើលយូរឆ្នាំមកហើយឥតយល់មួយចំណុចទេ, សុំលោកនាយក្រុមជួយពន្យល់ខ្លះផង ។

ស៊ីផានសម្លឹងម្ចាស់កោះពីម្នាក់ទៅម្នាក់ដូចជាគ្មានឃើញចំណុចណាគួរសង្ស័យថាគាត់ចំអក នោះ ទើបឆ្លើយ :

– សុំអភ័យលោកម្ចាស់តាមត្រង់ចុះ, មុនដំបូងខ្ញុំក្រឡេកមើលគំនូសអក្សរក្រវេមក្រវាម ដូចដង្កូវនេះឯង ស្រាប់តែជីពចរខ្ញុំញាក់ញ័រ – ដល់ខ្ញុំមើលអក្សរមួយទៀតជីពចរវៀងលោតញ័រទៀត ...

ដោយចង្អុលគួរអក្សរលើជញ្ជាំងថ្មពន្យល់ម្ចាស់កោះជាហូរហែ, តែតាចាស់ទាំងពីរធ្វើមុខស្ងៀមហាមាត់ធុង ។ មាណពឃើញសភាពប្លែកបែបនេះក៏ដាច់ចិត្តសួរថា :

– ខ្ញុំបាននិយាយខុសឬ ?

ម្ចាស់កោះត្រកួលឡើងឆ្លើយតពាក់តពុប :

– អូ ! លោក ... នាយក្រុមមើលគំនូសមួយ ៗ ដូចដង្កូវវារឬ ? មិនមែនមើលអក្សរពេញតួទេ ... បើអ៊ីចឹងម៉េចលោកយល់ន័យកំណាព្យបុរាណ ដែលសុទ្ធតែបាលី ?

ស៊ីផានមុខក្រហមឆ្អិន :

– តាំងពីតូចមកខ្ញុំឥតដែលរៀនអក្សរទេ ម៉ោះហើយខ្ញុំមានភ្នែកដូចមនុស្សខ្វាក់ , គួរខ្មាសគេណាស់ ។

ម្ចាស់កោះភ្ញាក់ក្រញាងស្រែកសួរព្រមគ្នា:

–លោកមិនចេះអក្សរមែនឬ ?

មាណពត្រឹក្សាលបួយៗ:

-បាទ, មិនចេះមែន ! តាំងពីត្រឡប់ទៅវិញខ្ញុំរកអាស៊ីវជួយបង្រៀនទាល់តែចេះគិតគេ, ទំៗ គេមើលងាយខ្ញុំណាស់, ថាខ្ញុំល្ងីល្ងើឥតចេះ « នខ្វាក់ » មួយសោះ ។

ម្ចាស់កោះទាំងពីរនាក់ មើលមុខស៊ីផងានមួយសន្ទុះហាក់មិនទាន់ជឿសំដីនាយ, តែគ្មានឃើញអ្វីគួរចាប់ថ្នាក់ថានាយលាក់ពុតឬបោកបញ្ឆោតសោះ ។ ម្ចាស់កោះគិតមិនលេចឈររវើរវាយបណ្តោតអារម្មណ៍មួយសន្ទុះទើបសួរទៀត :

– បើលោកមិនចេះអក្សរ, បានអ្នកណាជួយពន្យល់ពាក្យសម្រាយក្នុងបន្ទប់ថ្មទាំងឡៃមុននេះ ?

– គ្មានអ្នកណាពន្យល់ទេ, លោកតាចិនអស់លោកក្លាហានខានស្រុកលាវគុនពន្យល់ពីរបីម៉ាត់ដែរ តែខ្ញុំឥតស្តាប់បានបន្តិចណាទេ ។ ខ្ញុំ... ខ្ញុំគ្រាន់តែពិនិត្យរូបគំនូរអស់នោះហើយបណ្តោតអារម្មណ៍ទៅណា ផ្តេសផ្តាស ស្រាប់តែឃើញហាក់ដូចជុំពតពុកប្លែងៗរលេចញ៉ាំងទោះកម្រើក, ដីពេលខ្ញុំក៏ញាក់ញ័រ រាល់ពេលតាមគំនូរ ឯធាតុក្តៅរត់រស៊ីបពេញខ្លួន ។

តាត្រកូលមុពោលរវើ :

–លោកមិនចេះអក្សរទេ . . . តែលោកយល់ន័យកំណាព្យបុរាណ . . . លោកយល់ពាក្យបាលី... នេះមកពីហេតុអី ?

តាត្រកូលឡុងពោលបន្ត :

–ឬក៏ជាព្រេងសំណាងលោកពីអតីតជាតិ ?

ស្រាប់តែតាមុខស្រ្កាំជើងស្រែកភ្លាម :

–យល់ហើយលោកបង ! ខ្ញុំយល់ហើយ !

តាឡុងស្រឡាំងកាំងសម្លឹងមុខប្អូនធម៌គាត់មួយនាទីក៏យល់ភ្លាម ។

ត្បិតតាចាស់ទាំងពីរ ធ្លាប់រស់នៅជាមួយគ្នាយ៉ាងជិតស្និទ្ធយូរហើយ, ក៏តែយុទ្ធសិល្បៈនិងកម្លាំងប្រាជ្ញាក៏មិនស៊ីសងគ្នាដែរ ។ តាមុមិនសូវនិយាយ តែគិតច្រើន, តាឡុងនិយាយច្រើនមិនសូវមានពេលគិត ។ រាល់ពេលដោះស្រាយបញ្ហាពិបាក តាមុយល់ឃើញមុនជានិច្ច ។ តឡុងគាត់ក្តាប់ដៃគ្នាយ៉ាងណែន បញ្ចេញទឹកមុខសប្បាយលាយនឹងការជូរចត់សោកស្តាយ ។

Khmer Story Lovers

បន្ទាប់ពីនោះមកតាត្រកូលឡុងពោល :

- មកពីលោកនាយក្រុមស៊ីមិនចេះអក្សរ បានជាដោះស្រាយពាក្យពេចន៍កំណាព្យបុរាណមិនបាន ។ តែប៉ុណ្ណោះបងប្អូនខ្ញុំដាច់ចិត្តលាចាកលោកនេះដោយស្ម័គ្រហើយ !

- យី ! លោកម្ចាស់ ... មានប្រសាសន៍ថាម៉េចអ៊ីចេះ ?

តាឡុងដកដង្ហើមធំ :

- ហ៊ឺ ! ពេលនេះយើងខ្ញុំយល់ហើយ ! ពាក្យសម្រាយនៅលើផ្ទាំងសុទ្ធតែដឹកនាំយើងខ្ញុំឲ្យយល់ខុស, ព្រោះអ្នកចង់ស្រាវជ្រាវទាំងប៉ុន្មានសុទ្ធតែមើលអក្សរវែកញែករកអត្ថន័យមុនគំនូរដូចៗគ្នា ។

ស៊ីផានសួរដោយឆ្ងល់ :

- បើអ៊ីចឹងអក្សរនៅក្បែរគំនូរឥតបានប្រយោជន៍អីទេឬ ?

- ហ៊ឺ ! មិនត្រឹមតែគ្មានប្រយោជន៍ប៉ុណ្ណោះទេ, វាធ្វើឲ្យយើងដើរផ្លូវខុសថែមទៀតផង ។ ប្រសិនបើគ្មានពាក្យសម្រាយម៉្លេះសមបងប្អូនយើងពិនិត្យគំនូរបានការខ្លះៗហើយ ។ ស្តាយណាស់ !...

តាមុបន្តទាំងក្តីមួហ្មង:

- រីពាក្យបាលីក៏មិនមែនអក្សរបុរាណត្រឹមត្រូវដែរ, គ្រាន់តែ...គ្រាន់តែគូសវាសតាមសរសៃជីពចរក្នុងខ្លួនមនុស្សឲ្យប្រហាក់ប្រហែលអក្សរប៉ុណ្ណោះ ! ហ៊ឺ ! . . . សែសិបឆ្នាំ . . . សែសិបឆ្នាំកន្លងផុតទៅឥតបានការអ្វីសោះ !

- អូ ! លោកប្អូនអើយ, សក់ប្អូនស្កូវអស់ហើយ !

តាមុងើបមុខមើលបងបន្តិចរួចបញ្ចេញសម្លេងតាមច្រមុះពុហ៊ឹះ ឥតចេញវាចា, តែមាណពមីនថាគាត់ចង់ពោលសងវិញថា សក់បងក៏ស្កូវអស់ដែរ ។

ម្ចាស់កោះទាំងពីរសម្លឹងមុខគ្នាដកដង្ហើមវែង ។ ក្នុងមួយភ្លែតសោះគាត់ប្រែក្លាយជាតាចាស់ច្រុងច្រោមសក់ស្កូវសំព្រោងខុសឆ្ងាយពីពេលជួបជុំជប់លៀងបបរក្នុងបន្ទប់កិត្តិយសសម្បើមអស្ចារ្យ ។

ស៊ីផាននៅមិនអស់ឆ្ងល់សួរទៀត :

- ហេតុអីបានជាគេសរសេរអក្សរច្រើនលើផ្ទាំងឲ្យយល់ខុសទទេៗ ?

តាឡុងគ្រវីក្បាល :

- គេមានគោលបំណងបែបណា យើងទាយមិនត្រូវទេ ។ ប្រហែលបុព្វបុរសនោះ មិន

ចង់ឲ្យយើងហាត់ចេះផាយៗ ឬមានជនទំពីរមកសរសេរថែមបន្ថែមផ្លូវអ្នកគុណនិយមជំនាន់ក្រោយ ក៏បានដែរ ។

តាមុំពោលថា :

– ថាម៉្យាងទៀតគឺបុព្វបុរសនោះមិនសូវចូលចិត្តអ្នករៀនសូត្រអក្សរសាស្ត្រ ទើបធ្វើជាអន្ទាក់បែបហ្នឹង ដើម្បីកេងប្រយោជន៍ទុកឲ្យមនុស្សមិនចេះអក្សរផ្លូវលោកធាយក្រុមស៊ី ?

តាគ្រូកុលឡុងដកដង្ហើមធំម្ដងទៀត :

– មនុស្សសាក្រោយគ្មានអ្នកណាអោះអាងអាលលំណាង សម្ងាត់នៃបុព្វបុរសជាន់មុនឡើយ ។

ស៊ុំផានយើញតាចាស់ទាំងពីរ ផែង ស្ងាហាប់ សៀវភៅ ឋូចមុខធាយកណាំនកសួរគាត់ណាស់ ,

នាយពោលប្រាប់គាត់ភ្លាម :

– លោកម្ចាស់ទាំងពីរកុំបារម្ភ, បើវិជ្ជាចាំងនេះមានប្រយោជន៍មែន ខ្ញុំត្រូវតែពន្យល់តាំងពីដើម ដល់ចប់ជូនលោកចេះផង ។ ឥឡូវសូមគ្រូឡប់ទៅបន្ទប់ទីមួយ . . .

ម្ចាស់កោះគ្រូកុលឡុងគ្រវីក្បាលពោលទាំងញញឹម:

– យើងខ្ញុំសុំអរគុណលោកនាយក្រុមជាអនេក, លោកប្អូនមានចិត្តស្មោះត្រង់កិរិយាមារយាទស្លូតបូតត្រឹមត្រូវណាស់ត្រូវមានសំណាងដូច្នេះឯង ។ សូមលោកប្អូនយកកំណាប់ទិព្វនេះប្រើការក្នុងពិភពគុនជួយលើកដំកើងកេរ្ដិ៍ឈ្មោះនិងឋានៈជីវភាពអ្នកក្លាហានទាំងអស់តាមផ្លូវសុចរិតយុត្តិធម៌តទៀងទៅ ។

ម្ចាស់កោះគ្រូកុលមុខញញឹមញោបល់ :

– បើអត្ថន័យនៃកម្ពុរបុរាណត្រូវដោះស្រាយជ្រះស្រឡះហើយ, យើងខ្ញុំឥតត្រូវបារម្ភអ្វីទៀតទេ , ប្អូនប្រុសហាត់ចេះចប់ក៏ដូចជាប្អូនខ្ញុំចេះដែរ . យើងពេញចិត្តណាស់ ។

ស៊ុំផានពោលអង្វរ:

– បើដូច្នេះសូមអស់លោកឲ្យខ្ញុំពន្យល់អក្សរក្រវេមក្រវាមក្នុងបន្ទប់នេះបានដែរ ?

ម្ចាស់កោះគ្រូកុលឡុងញញឹមស្ងួត:

– បើមានអ្នកចេះយុទ្ធសិល្បៈអស់នេះហើយកំនួរពិសិដ្ឋអក្សរលើផ្ទាំងក៏ត្រូវលុបចោលដែរ, លោកប្អូនមើល ?

ស៊ុំផានងាកមើលផ្ទាំង ក៏ភ័យស្ញែកស្ញាំងព្រោះផ្ទាំងថ្មរបើកទាំងផ្ទាំងៗរបេះអក្សរជ្រុះខ្ទេច

ៗ

ខ្ទីអស់ ទាំងរូបគំនូរដែលចារពីក្បួនយុទ្ធសិល្បៈ ក៏ឡើងប្រេះហើយរបេះធ្លាក់មកដី ជាបន្តបន្ទាប់គ្នាដែរ ។

មាណពទ្រាំអត់ឆ្ងល់ពុំបាន ក៏បន្លឺសួរម្ចាស់កោះ :

– លោកម្ចាស់ , មូលហេតុអ្វីបានជាថ្មនៃជញ្ជាំង របេះធ្លាក់មកឯងៗយ៉ាងដូច្នេះ ?

តាចាស់តបដោយទឹកមុខស្ងប់ :

– អ្វីៗនៅលើលោកយើងនេះតែងមានទីកំណត់ មិនថាតែមនុស្ស ឬសត្វ សូម្បីតែវត្ថុធម្មជាតិ ក៏ធ្លាក់ក្នុងសភាពនេះដែរ ។ ហេតុនេះអ្វីដែលឧប្បត្តិកឡើង អ្វីនោះក៏តែងវិនាសសាបសូន្យទៅវិញដោយឯកឯងដែរ នេះជាសច្ចភាព ។

បង្អង់បន្តិច , គាត់បន្តទៅទៀត :

– ជញ្ជាំងថ្មនេះ មានអាយុរាប់សិបឆ្នាំមកហើយ ប្រហែលជាពេលនេះដល់កាលកំណត់ត្រូវលាយទៅវិញទេដឹង ? ... ចាត់ទុកជាភ័ព្វសំណាងរបស់ប្អូនប្រុសហើយ ប្រសិនបើវារលំ មុនពេលដែលប្អូនមើលយល់វា គឺជារឿងគួរឲ្យសោកស្ដាយណាស់ ។ ប៉ុន្តែពេលនេះផ្ទាំងគំនូរក្នុងបន្ទប់ថ្មទាំងប៉ុន្មាន ស្ថិតនៅក្នុងខ្លួនរបស់ប្អូនហើយ គ្មានអ្វីគួរឲ្យស្ដាយស្រណោះទេ !

ស៊ីផាន ស្ដាប់ចប់ មានចិត្តរំភើបរីករាយជាអនេក ដោយនាយគិតថា: គឺជាភ័ព្វវាសនារបស់នាយម្យ៉ាង ម្យ៉ាងទៀត ប្រសិនចេះអក្សរជ្រៅជ្រះវិញ ក៏ប្រហែលជាបាននៅសំរាកលើកោះឡុងមុរាប់សិបឆ្នាំ ដូចគេដូចឯងដែរហើយមើលទៅ ! តែនាយស្រងាកចិត្តនឹកអាណិតម្ចាស់កោះទាំងពីរ ដែលបានចំណាយ ននដាន និងកម្លាំងអស់រាប់ឆ្នាំ ក្នុងការស្រាវជ្រាវពីផ្ទាំងគំនូរនេះ សំរេចសំរួលទៅគ្មានបានទទួលលទ្ធផលអ្វីជាដុំកំភួនសោះ ។

មាណពតបទៅតាចាស់វិញ:

– ខ្ញុំបាទបានមកដល់ទីនេះ ក៏ដោយសារតែលោកម្ចាស់ដែរ ... ខ្ញុំបាទគ្មានគំនិតលោភលន់អ្វីទាំងអស់ ។ ការដែលខ្ញុំបាទ មើលយល់នូវផ្ទាំងគំនូរទាំងនេះ ក៏ជារឿងមួយកើតឡើងដោយចៃដន្យដែរ សុំលោកម្ចាស់អភ័យទោសផងទៅចុះ !

ម្ចាស់កោះញញឹមតប:

– ប្អូនប្រុសមានចរិតថ្លៃថ្នូរ ឫកពាសមរម្យ ស្លូតបូត និងស្មោះត្រង់ សមជាកំពូលគុនទៅថ្ងៃ

ក្រោយមែន ៗ ការពិតបងប្អូនយើង គ្មានគំនិតគេង្សៀតបង្អស់ ស្មើរប្អូនទេ យើងមានតែចិត្ត សប្បាយរីករាយណាស់ ដោយសេចក្ដីសង្ឃឹមរបស់យើង មានពន្លឺឡើងវិញ តែប៉ុណ្ណោះយើង ស្លាប់មិនភ្លេកផិតហើយ --- ៗ

គាត់បង្អង់បន្តិចទើបបន្ត:

- ប្អូនប្រុសត្រូវចងចាំថា ពិភពកុន សំបូរទៅដោយមនុស្សទុច្ចរិតណាស់ ... ការដែលប្អូនមានចិត្ត ស្មោះត្រង់ហួសហេតុដូច្នេះ ធ្វើឲ្យមានគ្រោះថ្នាក់ណាស់ ហេតុនេះមុននឹងទាក់ទងចងមិត្តជាមួយនរណាម្នាក់ ប្អូនត្រូវពិនិត្យពិចារណាឲ្យបានដិតដល់ជាមុនសិន ៗ មួយវិញទៀតវិជ្ជាកុនមានតម្លៃខ្ពង់ខ្ពស់ ថ្លៃថ្នូរ ទទួលការគោរពរាប់អានពីអ្នកកុននិយមទូទៅបាន លុះត្រាតែយើងប្រើប្រាស់វា នៅក្នុងផ្លូវសុចរិត យុត្តិធម៌ ត្រឹមត្រូវ ៗ យ៉ាងណាមិញ , បើយើងប្រើវាក្នុងផ្លូវខុសវិញ វានឹងផ្ដល់ទុក្ខទោស ដល់រូបយើង មិនខាន ៗ យើងមានតែពាក្យផ្ដាំផ្ញើប៉ុណ្ណោះទេ ទុកជាចំណងដៃដល់ប្អូន ក្នុងការដែលយើងបាន ស្គាល់គ្នានេះ មើលទៅយើងប្រហែលជាគ្មានឱកាស ជួបគ្នា ជាថ្មីម្ដងទៀតទេ... ៗ

Khmer Story Lovers

(នៅមានត)